ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៦០
ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០
សាលដីកា
លេខ ៣៧៦ VIII
ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន
២.ឯកឧត្តម [redacted] ជាចៅក្រម
៣.ឯកឧត្តម [redacted] ជាចៅក្រម
៤.ឯកឧត្តម [redacted] ជាចៅក្រម
៥.ឯកឧត្តម [redacted] ជាចៅក្រម

### ចៅក្រមរបាយការណ៍

ឯកឧត្តម [redacted]

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៥៤៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទ [redacted] ចាន់ធា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រII "រ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

- ជនជាប់ចោទ ៖ ឈ្មោះ [redacted] ចាន់ធា ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរអ្នកបើកបររថយន្ត មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំកណ្តោលដុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ និងទីលំនៅ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] " ម្តាយឈ្មោះ [redacted] "រ" ជានីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

.ឃុំខ្លួនតាមដីកាបង្គាប់លេខ ៤៩៥ ចុះថ្ងៃទី២០ សីហា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តកំពង់ស្ពឺ ។

**ជាប់ចោទពីបទៈ** បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច ដែលបទបញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ ប្រព្រឹត្តនៅភូមិកំណប់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-មានលោក[redacted]ជល្លា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

- **អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ៖** ឈ្មោះ[redacted]ចាន់ថា ហៅ ស្មាញ ភេទប្រុស អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិផ្សារត្រពាំងក្រឡឹង ឃុំគិរីវ័ន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted] "រ" ។

- **ជនរងគ្រោះ**

១-ឈ្មោះ[redacted]រតនា ភេទស្រី អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

២-ឈ្មោះ[redacted]វិច្ឆិកា ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

៣-ឈ្មោះ[redacted]សុភា ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

- **ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីៈ** ឈ្មោះ[redacted]ចន្ធី ហៅ បារាំង ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

- **ដើមបណ្តឹងរដ្ឋប្បវេណី ៖**

១-ឈ្មោះ[redacted] ឃីម ភេទស្រី អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

២-ឈ្មោះ[redacted]រតនា ភេទស្រី អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិរំលេច ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

៣-ឈ្មោះ [redacted] វុទ្ធថា ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

៤-ឈ្មោះ[redacted] សារុធ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

-មានលោ[redacted] ម្ញូរ៉ា ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ឃីម ។



Scanned with CamScanner

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ១៥ និង៤០នាទី នៅលើផ្លូវលេខ ១៣០ ត្រង់ចំណុចលើស្ពានអំពែភ្នំ ភូមិកំណាប់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានករណីបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ ដែលបង្កឡើងដោយអ្នកបើករថយន្តម៉ាក HINO ពណ៌ខៀវ ពាក់ស្លាកលេខ ភ្នំពេញ 3A-3547 បើកបរដោយឈ្មោះ[redacted]ចាន់ធា ភេទប្រុស អាយុ ២២ឆ្នាំ ដោយអ្នកបើកបរមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តឱ្យបានច្បាស់លាស់ បើកបរដោយគ្មានប័ណ្ណបើកបរ បើកក្នុងល្បឿនលឿនដោយជាន់ហ្វ្រាំងមិនស៊ី ក៏បានបើកទៅបុករថយន្តមួយគ្រឿងទៀតម៉ាក HYUNDAI ពណ៌ស ពាក់ស្លាកលេខ កំពង់ចាម 3A-5305 បើកដោយឈ្មោះ [redacted] វិចិត្រ កំពុងតែឡើងលើស្ពាន បុករុញថយក្រោយទៅបុកម៉ូតូ ០២គ្រឿង ទៀត ធ្វើឱ្យអ្នកជិះម៉ូតូម្នាក់ឈ្មោះ [redacted] រតនា ភេទស្រី អាយុ ១៦ឆ្នាំ បានស្លាប់ ឈ្មោះ [redacted] វិច្ឆិកា ភេទស្រី អាយ[redacted]សុភា ភេទស្រី រងរបួសធ្ងន់ និងឈ្មោះ [redacted]ចន្ធី ភេទស្រី រងរបួសស្រាល ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩៤ “ង” ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ចាន់ធា ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរបើករថយន្ត ទីកន្លែងកំណើតនៅភូមិថ្មី ឃុំកណ្តោលដុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូ[redacted] ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted]” ម្តាយឈ្មោះ[redacted]” ជានីតិជន ទោសពីមុនគ្មាន ។

ដាក់ពន្ធនាគារចំនួន ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឱ្យរបួស និងស្លាប់អ្នកដទៃ ប្រព្រឹត្តនៅភូមិកំណាប់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២-ប្រគល់ម៉ូតូម៉ាកហុងដា C125 ពណ៌ខ្មៅ ស៊េរី២០០៨ ពាក់ស្លាកលេខ កំពង់ស្ពឺ 1B-7614 ឱ្យឈ្មោះ[redacted] វិច្ឆិកា ។

៣-ប្រគល់ម៉ូតូហុងដា C125 ពណ៌ខ្មៅ ស៊េរី២០១៥ ពាក់ស្លាកលេខ កំពង់ស្ពឺ 1J-6910 ឱ្យឈ្មោះ [redacted]ចាន់ធី ។

៤-ឱ្យឈ្មោះ[redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជំងឺជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនា ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។



Scanned with CamScanner

៥-ឱ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជំងឺជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឹម ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។

៦-ឱ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជំងឺជាប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុធ ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។

៧-ឱ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជំងឺជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វុទ្ធថា ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។

៨-ឱ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជំងឺជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ចន្ទី ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ អឿន ចាន់ធា, ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] យឹម , ឈ្មោ[redacted] សារុធ, ឈ្មោះ [redacted] វុទ្ធថា ឈ្មោះ [redacted]ចន្ទី និង ចាត់ទុកចំពោះមុខអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឈ្មោះ[redacted] ចាន់ថា និងកំបាំងមុខឈ្មោះ [redacted]រតនា ។

ទុកសិទ្ធប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ង" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឹម ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ង" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៤ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ង" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រII "វ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធា មិនអាចទទួលយកបាន ។



Scanned with CamScanner

២-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានចំពោះផ្នែកអាជ្ញា ។

៣-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃឹម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានចំពោះផ្នែកអាជ្ញា ។

៤-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ង" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល ។

៥-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៦-សាលដីកានេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ កំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោ[redacted] ចាន់ថា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃឹម ។

ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៥៤៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធា ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រII "វ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានសុំថា៖ ក្នុងសារណារបស់ជនជាប់ចោទឈ្មោ[redacted] ចាន់ធា បានសារភាពថា រថយន្តម៉ាក HYUNDAI ថយក្រោយប៉ះគេស្លាប់ ទើបខ្លួនបុកបន្តិចតាមក្រោយដោយព្យាយាមជាន់ហ្វ្រាំងដែរតែជាន់មិនស៊ី ។ សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចមកនេះត្រឹមត្រូវហើយ ។

ហេតុដូច្នេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រII "វ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

+លោក [redacted] ផល្លា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនបានទទួលស្គាល់ថា កូនក្តីរបស់ខ្លួនធ្វើបណ្តឹងឧទ្ធរណ៍ដោយហួសរយៈពេលកំណត់ពិតមែន ប៉ុន្តែអ្វីដែលកូនក្តីខ្លួនប្តឹងសាទុក្ខមកនេះ គឺដោយសារតែគាត់បានអនុវត្តទោសក្នុងពន្ធនាគារបានរយៈពេល ២ឆ្នាំ ជិត៣ខែហើយ បើគិតពីថ្ងៃចាប់ខ្លួនគាត់ជិតដល់ថ្ងៃដែលត្រូវរួចទោសហើយ ម្យ៉ាងទៀត ការប្រព្រឹត្តនេះគាត់គ្មានចេតនាទេ ទើបគាត់មានបំណងស្នើសុំឱ្យតុលាការកំពូលផ្តល់នូវស្ថានសម្រាលទោសដល់រូបគាត់ ។



Scanned with CamScanner

សំណូមពរ សូមឱ្យតុលាការមេត្តាកាត់តម្រឹមទោសឱ្យកូនក្តីខ្លួនផង ដោយគិតពីថ្ងៃចាប់ខ្លួន ។

+ជនជាប់ចោទឈ្មោ[redacted]ចាន់ធា បានឆ្លើយថា៖ សូមឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោស ឱ្យខ្លួនផង ។

+ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងអស់បានសំណូមពរថា៖ សុំឱ្យតុលាការកំពូលសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រII “វ” ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងមេធាវីធ្វើសេចក្តីសន្និដ្ឋានការពារ

-ក្រោយពីបានស្តាប់សំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សា ពិចារណាត្រឹមត្រូវហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៤៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទ ឈ្មោ[redacted]ចាន់ធា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបាន តាមបញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧, មាត្រា ៤១៨ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា តាមពាក្យសុំពឹងពាក់មេធាវីរបស់[redacted]ចន្ថា ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២១ ត្រូវជាបងប្រុសបង្កើតរបស់ជនជាប់ចោទឈ្មោះ [redacted]ចាន់ធា និងនាពេលសវនាការ ជនជាប់ចោទបាន ឆ្លើយទទួលយកមេធាវីឈ្មោះ[redacted]ផល្លា ការពារឱ្យខ្លួន ។

៣-យល់ឃើញថា សាលដីកាសាលាឧទ្ធរណ៍ភ្នំពេញលេខ ១២៤ ក្រII “វ” ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ចំណុចទី១ បានសម្រេចមិនអាចទទួលយកបាននូវបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោ[redacted] ចាន់ធា ដោយមូលហេតុហួសអំឡុងពេលមិនត្រូវតាមកំណត់ច្បាប់ មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងនាពេលសវនាការនៅតុលាការកំពូល មេធាវីរបស់ជនជាប់ចោទក៏បានទទួលស្គាល់ថា អំឡុងពេលប្តឹង ឧទ្ធរណ៍បានហួសកំណត់ច្បាប់មែន និងបានស្នើសុំបណ្តឹងសាទុក្ខ និងបើមិនទទួលហាក់បាត់ឱកាសពិនិត្យ អំពីទោសរបស់កូនក្តីខ្លួន ការលើកឡើងរបស់មេធាវីហាក់មិនមានបញ្ញត្តិច្បាប់ណាមួយគាំទ្រសំណើសុំ នេះទេ ។

៤.យល់ឃើញថា តាមការយល់ឃើញក្នុងចំណុចទី៣ ខាងលើ ឃើញថា ជនជាប់ចោទបាន ផ្តោះសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍រួចហើយ ដូច្នេះ ទោះបីបណ្តឹងសាទុក្ខរបស់ជនជាប់ចោទស្ថិតក្នុងអំឡុងពេល ក៏ដោយ តុលាការកំពូលមិនអាចលើកយកបញ្ហាផ្សេងពីនេះមកពិចារណាបានទេ ដោយហេតុថា ជនជាប់ចោទ ក៏ផ្តោះសិទ្ធិក្នុងការប្តឹងសាទុក្ខដែរ ។



Scanned with CamScanner

## ហេតុដូច្នេះ
## សម្រេច

១. បដិសេធបណ្តឹងសាទុក្ខលេខ ៥៤៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទ [redacted] ចាន់ធា ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២៤ ក្រII "រ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ។

-ឯកឧត្តម [redacted] ជាប្រធាន

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-លោកស្រី [redacted] ជាក្រឡាបញ្ជី

---

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។

ថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner